**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៤៦៥
ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៣
**<u>សាលដីកា</u>**
លេខ:១៩៨
ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម .......... ជាប្រធាន
២-លោក .......... ជាចៅក្រម
៣-លោក .......... ជាចៅក្រម
៤-លោក ............ ជាចៅក្រមរបាយការណ៍
៥-លោក ............ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា ...................

**<u>តំណាងមហាអយ្យការ</u>**

-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១៥៨ (ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥៧០ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង:

- ដើមចោទឈ្មោះ អកស ហៅ យកស ដើមបណ្តឹងសាទុក្ខ ភេទប្រុសអាយុ ២៧ឆ្នាំជាតិខ្មែរ មុខរបរ និស្សិតទីលំនៅផ្ទះលេខ៥ ផ្លូវលេខ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ។ឪពុកឈ្មោះ យិន សារ៉ាត(ស ) ម្តាយឈ្មោះថោង សាម៉េត(រ) នៅលីវ ។

មានមេធាវីលោក .............

- និងចុងចម្លើយឈ្មោះ សចជ ចុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ៣៦ឆ្នាំជាតិខ្មែរ មុខរបរ រត់ម៉ូតូឌុប ទីលំនៅផ្ទះលេខ៥ ផ្លូវលេខ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។ ឪពុកឈ្មោះ សៀង ហ៊ាង(ស) ម្តាយឈ្មោះអ៊ូ សាន (ស) ប្រពន្ធឈ្មោះ ស្បោង ចិន្តា មានកូន៤នាក់ ។

មានមេធាវីលោក ..............

អំពីវិវាទ: ប្តឹងទាមទារបែងចែកទ្រព្យមរតក ផ្ទះលេខ៥ ផ្លូវ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ និងប្តឹងសុំឱ្យស្បោង ចន្ទី និង ប្រពន្ធ ព្រមទាំងកូនចុះចេញពីផ្ទះ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៦៥ ចុះថ្ងៃទី០៤ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ៣២៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ របស់លោកមេធាវី ............(តំណាងឱ្យឈ្មោះ ...........)មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥៨(ឈ) ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៥-០២-២០០១ របស់ដើមចោទឈ្មោះ អកស ថាខ្លួនប្តឹង សុំឱ្យឈ្មោះ សចជ និងប្រពន្ធឈ្មោះ ស្បោង ចិន្តា ព្រមទាំងកូនចុះចេញពីផ្ទះលេខ៥ ផ្លូវលេខ៤៣៦ សង្កាត់ បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលពីម្តាយខ្លួន(ម្តាយចិញ្ចឹមឈ្មោះអស) នៅរស់គាត់បានឱ្យឈ្មោះ សចជ មកស្នាក់នៅបណ្តោះអាសន្ន។ លុះដល់ថ្ងៃទី០១-០៥-៩៧ ម្តាយរបស់ខ្លួនស្លាប់ ពេលនោះ ខ្លួនឱ្យឈ្មោះ សចជ និងប្រពន្ធកូនចុះចេញពីផ្ទះរបស់ខ្លួន ព្រោះឈ្មោះនេះពុំមានសិទ្ធិស្នាក់នៅក្នុងផ្ទះនេះបន្តទៀតឡើយ ។

ប៉ុន្តែត្រូវឈ្មោះ សចជ បដិសេធមិនព្រមចុះចេញ ហើយបែរជាទារឱ្យខ្លួនប្រគល់ប្រាក់ឱ្យ គាត់ចំនួន៣០.០០០ដុល្លា ទើបគាត់ព្រមចុះចេញពីផ្ទះរបស់ខ្លួន ។

-តាមពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី១២-១១-២០០១ របស់ដើមចោទឈ្មោះ អកស ថាៈខ្លួនប្តឹងទាមទារបែងចែកមរតកនូវផ្ទះលេខ៥ ផ្ទះលេខ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំក្ខារមន រាជធានីភ្នំពេញពីឈ្មោះ សចជ និងប្រពន្ធឈ្មោះ សចន ដែលជាទ្រព្យសម្បត្តិរបស់ម្តាយចិញ្ចឹមខ្លួនឈ្មោះ អស បានន្សល់ទុក ។

ដោយហេតុថា កាលពីឆ្នាំ១៩៧៩ ម្តាយចិញ្ចឹមរបស់ខ្លួនជាស្ត្រីមេម៉ាយ បានចូលមករស់នៅក្នុងផ្ទះលេខ៥ ផ្ទះលេខ៤៣៦ សង្កាត់បឹងត្របែកនេះ ដូចមានប័ណ្ណគ្រួសារលេខ២១៧ សៀវភៅលេខ៣១/២៤០១-១៩៨១ បញ្ជាក់ជូនស្រាប់ដែលមានឈ្មោះគាត់ជាមេគ្រួសារ និងមានខ្លួនប្អូនៗ របស់គាត់នៅក្នុងបន្ទុកហើយ នៅក្នុងឆ្នាំ១៩៨២ ម្តាយចិញ្ចឹមរបស់ខ្លួនបានយកប្តីមួយទៀតឈ្មោះ សហ ។

ក្នុងរយៈពេល គាត់រស់នៅជាមួយសៀងហ៊ាង កូនដើមរបស់ សហ ឈ្មោះ សចជ ពុំបានមករស់នៅជាមួយឡើយ គ្រាន់តែយូរៗ មកលេងឪពុកម្តង ចំណែកខ្លួនបានរស់នៅជាមួយម្តាយចិញ្ចឹមជាប់ រហូត ។នៅថ្ងៃទី១២-០២-៩៧ ម្តាយចិញ្ចឹមរបស់ខ្លួន បានចែកដីទំហំ១៥ម គុណ១៩ម៨០ ស្ថិតក្នុង
ដីឡូត៍លេខ៥ ផ្លូវលេខ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ឱ្យទៅប្អូនគាត់ឈ្មោះ យសរ ដូចមានលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១២-០២-៩៧ ដោយមានលោកចៅសង្កាត់ឈ្មោះ បសរ ចុះហត្ថលេខា ដឹងឮទៀតផង បន្ទាប់មកនៅថ្ងៃទី០១-០៥-៩៧ ម្តាយចិញ្ចឹមខ្លួនបានស្លាប់ដោយពុំបានធ្វើបណ្តាំមរតកឡើយ ចាប់ពីពេលនោះមកឈ្មោះទេ សហ ដែលជាឪពុកចុងរបស់ខ្លួននៅគ្រប់គ្រង ។ ក្នុងរយៈពេលនោះឈ្មោះ សចជ ឧស្សាមកលេងឪពុកឈ្មោះ សហ រួចបានចូលមករស់នៅក្នុងបន្ទប់មួយក្នុងផ្ទះលេខ ៥ នេះ ។

ចាប់តាំងពីឈ្មោះ សចធ ចូលមករស់នៅគឺតែងតែមានទំនាស់ជាមួយខ្លួន ក្រោយមកទៀត នៅថ្ងៃទី១៨-០៩-២០០០ ឪពុកចុងចិញ្ចឹមរបស់ខ្លួនឈ្មោះ សហ ក៏បានស្លាប់ទៀត។ ចាប់ពីពេលនោះមក ឈ្មោះ សចធ អាងយ៉ាងចង់គ្រប់គ្រងផ្ទះលេខ៥ ទាំងមូល តែម្នាក់ឯង ដោយគេអះអាងថា ផ្ទះនេះជាផ្ទះរបស់ឪពុកគេ ហើយគេមើលមកខ្លួនជាសត្រូវរបស់គេទាំងពីរនាក់ប្ដីប្រពន្ធ ឃើញភាពលោភលន់យ៉ាងដូច្នេះទើបខ្លួនសំរេចចិត្តប្ដឹងមកតុលាការ ដើម្បីសុំឱ្យតុលាការធ្វើការបែងចែកមរតករបស់ម្ដាយចិញ្ចឹមខ្លួនឈ្មោះអ៊ុំ សាន បានបន្សល់ទុកទៅតាមផ្លូវច្បាប់ ។

- តាមបណ្ដឹងតប ចុះថ្ងៃទី២៧-០៤-២០០២ របស់មេធាវី ........... ជាមេធាវីតំណាងឱ្យ ឈ្មោះ សចធ បញ្ជាក់ថា ខ្លួនប្ដឹងតបទៅនឹងពាក្យបណ្ដឹង ចុះថ្ងៃទី២៥-០២-២០០១ និងបណ្ដឹងបន្ថែមចុះថ្ងៃទី១២-១១-២០០១ របស់ឈ្មោះ អកស ដែលទាមទារយកចំណែកមរតកនៃផ្ទះលេខ៥ ផ្លូវលេខ៤៣៦ សង្កាត់បឹងត្របែក ជាមួយកូនក្ដីខ្លួនឈ្មោះ សចធ។ ដោយហេតុថាឈ្មោះ សចធ ជាកូនបង្កើតរបស់ឈ្មោះ សហ និងនាង សសខ(បច្ចុប្បន្នស្លាប់) ឈ្មោះ សហ បានគ្នាជាប្ដីប្រពន្ធជាមួយឈ្មោះ អស តាំងពីឆ្នាំ១៩៧៩ លុះដល់ឆ្នាំ១៩៨០ ក៏បានរៀបការពេញច្បាប់ ហើយរស់នៅជាមួយគ្នាគ្រប់គ្រងផ្ទះលេខ៥ ៖ លេខ៤៣៦ ដោយមានឈ្មោះ សជធ ជាកូននៅក្នុងបន្ទុក តែពុំមានអ្នកណាម្នាក់មករស់នៅជាមួយជាប់លាប់ទេ ។

ឈ្មោះ សហ និង អស បានជួលផ្ទះមួយផ្នែកឱ្យទៅឈ្មោះ មឈ និងឈ្មោះ ដព ហើយទទួលប្រាក់ឈ្នួលផ្ទះជួលរហូតមកឈ្មោះ សចធ ដែលជាកូនក្ដីរបស់ខ្លួន បានស្នាក់នៅខាង ក្រោមជាមួយប្រពន្ធឈ្មោះ សចន មានកូន០៤នាក់ក្នុងបន្ទុក ។ ដោយឡែកឈ្មោះ ថសរ មានគ្រួសារក៏ទៅនៅខាងប្ដី ពុំដែលរស់នៅជាមួយឡើយ និង អកស ជាកូន ។ ឈ្មោះ អកល នេះគឺជាកូនរបស់ឈ្មោះ ថសរ មិនមែនជាកូនរបស់ឈ្មោះ អស ទេគឺគ្រាន់តែជាក្មួយតែប៉ុណ្ណោះ ។

នៅថ្ងៃទី០១-៥-៩៧ ឈ្មោះ អស ដែលត្រូវជាប្រពន្ធឈ្មោះ សហ រស់នៅជាមួយកូន បង្កើត សចធ និងកូនប្រសារស្រី និងចៅ ហើយទទួលប្រាក់ឈ្នួលផ្ទះរហូតមក និងជួយឲ្យអ្នកផ្សេងដោយសុខចិត្តស្នាក់នៅក្នុងបន្ទប់តូចមួយ ហើយឈ្មោះ សចធ នៅខាងក្រោមដដែល ។ នៅក្នុងចន្លោះឆ្នាំ១៩៩៧ នេះគ្មាននរណាមករស់នៅជាមួយទេ ក្រៅពីមកលេងធម្មតា ទៅមកទៅមកស្រាប់តែមានឈ្មោះឃិន ដែលត្រូវជាប្ដីរបស់ឈ្មោះ ថសម មកទាមទារថា ជាដីរបស់ខ្លួន ហើយតាំងខ្លួនជាមេគ្រួសារ តែមិនបានស្នាក់នៅឡើយ ។

ក្នុងរយៈពេល៣ឆ្នាំ ឈ្មោះ សហ និង សចធ ស្នាក់នៅរហូតមកទល់ថ្ងៃទី១៨-០៩- ២០០០ ឈ្មោះ សហ ក៏ស្លាប់បាត់ទៅទៀត គឺនៅសល់តែឈ្មោះ សចធ និងប្រពន្ធស្នាក់នៅជាកម្មសិទ្ធិ ស្រាប់តែមានឈ្មោះ អកស មកទាមទារជារបស់ខ្លួនទៀត ដោយអួតអាងថាខ្លួនគឺជាកូនចិញ្ចឹមរបស់ឈ្មោះ អស ហើយមកទាមទារចំណែកមរតក ដែលឈ្មោះនេះ គឺគ្រាន់តែជាក្មួយ និងមិនដែលរស់នៅជាមួយសោះទេ។

តបតាមខ្សែលោហិតបន្តមរតក មានតែឈ្មោះ សចធ តែម្នាក់គត់ ដែលជាកូនបង្កើតរបស់លោក សហ ដែលជាអ្នកទទួលស្នង រីឯលោក សហ និង អស ពុំមានកូនទេ ហើយឈ្មោះ សចធ ក៏បានស្នាក់នៅជាមួយរហូតទល់ពេលឪពុក-ម្តាយស្លាប់ ក៏អាចក្លាយជាម្ចាស់កម្មសិទ្ធិទៅហើយ ។

ខ្លួនសុំបដិសេធ លើបណ្តឹងនិងបណ្តឹងបន្ថែមរបស់ឈ្មោះ អកស ចោលដោយសុំឱ្យតុលាការសម្រេចផ្តល់មរតកផ្ទះលេខ៥ ផ្លូវលេខ៤៣៦ សង្កាត់បឹងត្របែកមកឱ្យកូនក្តីខ្លួនឈ្មោះ សចធ ជាកម្មសិទ្ធិពេញច្បាប់ផងចុះ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ១២ប្រ(ង)ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេច ។

១-ទទួលពាក្យបណ្តឹងកិច្ចការប្រញាប់ ចុះថ្ងៃទី២៥-០៥-២០០១ របស់ដើមចោទឈ្មោះ អកល ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២- ហាមឃាត់ឈ្មោះ សចធ និងប្រពន្ធឈ្មោះ សចដ មិនឲ្យលក់-ដូរ-បញ្ចាំផ្ទេរសិទ្ធិឬធ្វើអំណោយដល់អ្នកដទៃនូវផ្ទះលេខ៥ ផ្លូវលេខ៤៣៦ ក្រុម២១ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តីជាស្ថាពរ។

៣- បង្គាប់ឱ្យឈ្មោះ អកស បង់ប្រាក់ប្រដាប់ក្តីចំនួន៤០០០រៀល គឺពន្ធហ្នឹងនិងពន្ធចុះបញ្ជីក្តីចំនួន១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល និងរង្វាន់អ្នកប្រគល់ដីកាកោងចំនួន២០០០រៀលប្រាក់នេះកាត់យកពីប្រាក់ដែលដើមចោទ បានបង់ទុកជាស្រេច ។

៤- ដីកាសម្រេចនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥- ដីកាសម្រេចនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាម កំណត់ច្បាប់ ចាប់ពីថ្ងៃនេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ០៣(ង) ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៣ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី២៥-០២-២០០១ និងបណ្តឹងបន្ថែម ចុះថ្ងៃទី១២-១១-២០០១ របស់ដើមចោទឈ្មោះ អកល តំណាងដោយមេធាវីឈ្មោះ ................. មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២- ទទួលស្គាល់មេធាវីឈ្មោះ សអរ ជាតំណាងសិទ្ធិរបស់ដើមចោទតាមលិខិតចុះថ្ងៃទី២៦-០៣-២០០៣ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលពាក្យបណ្តឹងតប និងបន្ថែមចុះថ្ងៃទី១២-១១-២០០១ របស់ចុងចម្លើយឈ្មោះ សចធ តំណាងដោយមេធាវីសោម ............. ចុះថ្ងៃទី២៧-០៤-២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់និងបដិសេធចោលដោយផ្អែកគតិច្បាប់ ។

៤- ទទួលស្គាល់មេធាវីឈ្មោះ .......... ជាតំណាងរបស់ចុងចម្លើយឈ្មោះ សចធ តាម លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៤-០៤-២០០២ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥- ទទួលស្គាល់ប័ណ្ណគ្រួសារលេខ២១៧ ចុះថ្ងៃទី២៤-០១-១៩៨១ តាមសៀវភៅលេខ៣១ របស់គណៈកម្មាធិការប្រជាជនបដិវត្តក្រុង ជាត្រឹមត្រូវដោយចាត់ទុកថា ផ្ទះលេខ៥ ផ្លូវ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ជាទ្រព្យសម្បត្តិដោយឡែករបស់សពឈ្មោះដែលត្រូវជាម្ដាយចិញ្ចឹមឈ្មោះ អកស ប្រាកដមែន ។

៦-សម្រេចប្រគល់ផ្ទះលេខ៥ ផ្លូវ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ឱ្យទៅឈ្មោះ អកស ដែលត្រូវជាកូនចិញ្ចឹមសពឈ្មោះ អស កាន់កាប់ និងប្រើប្រាស់ចាប់ពីសាលក្រមនេះចូលជាស្ថាពរ។

៧- បង្គាប់ឱ្យឈ្មោះ សចធ បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១៨០០រៀល ប្រាក់ចំណាយលើដីកាកោះ៥០០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល សរុប៧០០០រៀល ប្រាក់នេះបាន កាត់យកពីប្រាក់៧០០០ រៀល ដែលដើមចោទ បានបង់រួច និងរឹបអូសប្រាក់ប្រដាប់ក្ដី ដែលបានបង់រួចចំនួន៧០០០រៀល ។

កាលបើហួសឧទ្ធរណ៍ ត្រូវបង្គាប់ឱ្យឈ្មោះ សចធ សងប្រាក់នេះទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ១% លើតម្លៃផ្ទះជាក់ស្ដែង ប្រាក់នេះត្រូវបង្វិលចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡា បញ្ជីទូទាំងប្រទេស២០% ប្រាក់នេះត្រូវឱ្យដើមចោទបង់ទុកជាមុន ទើបបង្គាប់ឱ្យចុងចម្លើយសងជាក្រោយ ។

៨- សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខមេធាវីតំណាងឱ្យដើមចោទ និងដើមចោទមេធាវីតំណាងចុងចម្លើយ និងចុងចម្លើយ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍០៥ (ឈ) ចុះថ្ងៃទី១៤ ខែកុម្ភៈឆ្នាំ២០០៣ របស់ ....... មេធាវីការពារឱ្យចុងចម្លើយ មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៣ (ង) ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញលើគ្រង់ចំណុចនៃសាលក្រម ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៥៨ (ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-០២-២០០៣ របស់លោក មេធាវី .................ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ០៣(ង) ចុះថ្ងៃទី០២-០១-២០០៣ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់។

៣- ប្រគល់ផ្ទះទំនាស់លេខ៥ ផ្លូវលេខ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ឱ្យទៅឈ្មោះសៀងចន្ទី កាន់កាប់គ្រប់គ្រង និងប្រើប្រាស់តទៅ។

៤-កាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០រៀលដែលចុងចម្លើយបានបង់ទុករួច ហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊ឹងចំនួន២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយ លើការប្រគល់ដីកាកោងចំនួន៥០០០រៀល អាជ្ញាធរចំនួន៥.០០០រៀល ។ នៅពេលសាលដីកានេះចូលជាស្ថាពរបង្គាប់ឱ្យដើមចោទបង់ប្រាក់ចំនួន១៣០០០រៀល នេះ ទៅចុងចម្លើយវិញ និងបង្គាប់ឱ្យដើមចោទបង់ពន្ធ សមាមាត្រ១% លើផ្ទះទំនាស់ ។

៥- សាលដីកានេទ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី១៧-១០-២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី២២-១០-២០០៣ ចំពោះមុខមេធាវី តំណាងគូក្តី បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ៣២៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ របស់លោកមេធាវី ......(តំណាងឱ្យឈ្មោះ អកស) មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥៨(ឈ) ចុះថ្ងៃទី២២ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤ របស់លោក អកស

បានឃើញ សារណាតបចុះថ្ងៃទី២៩ ខែ មេសា ឆ្នាំ ២០០៤ របស់លោក សចធ

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា៖

- បណ្តឹងសាទុក្ខរបស់ ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ១៥៨(ឈ) ចុះថ្ងៃទី២២-១០-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យនិង សម្រេច ។

បានស្តាប់ចម្លើយរបស់លោក អកស បានឆ្លើយថាៈ ដោយសាលាឧទ្ធរណ៍កាត់ក្តីពុំបានត្រឹម ត្រូវ ដោយផ្ទះនេះគឺកេរ្តិ៍របស់ម្តាយចិញ្ចឹមខ្លួន ហើយខ្លួនក៏បានមករស់នៅតាំងពី៧៩ មកម្ល៉េះពេលនោះខ្លួនមានអាយុប្រហែល៥ឆ្នាំហើយ ។ ម្តាយរបស់ខ្លួនបង្កើតឈ្មោះថោង សាម៉េត ហើយគាត់បានយកប្តីចុងទៀត ឈ្មោះ យសរ ដូចនេះ ទើបគាត់ត្រូវប្តូរត្រកូលរបស់ខ្លួនទៅជា យកស វិញ ប៉ុន្តែខ្លួនក៏បានបញ្ជាក់ហើយដែរ តាំងពីតុលាការថ្នាក់ក្រោម រហូតដល់តុលាការកំពូល គឺខ្លួនប្រើឈ្មោះ អកស ហៅ យកស ។ ចំណែកឯម្តាយចិញ្ចឹមរបស់ខ្លួនវិញ គាត់ឈ្មោះ អស ហើយគាត់បានសុំខ្លួនដែលត្រូវជាក្មួយបង្កើតរបស់គាត់ទៅធ្វើជា កូនចិញ្ចឹម និងចេញទៅរស់នៅជាមួយគាត់ នៅសាលាវត្តកោះដាបណ្តោះអាសន្នទេ ។ ការរស់នៅរបស់ខ្លួនគឺគាត់ទាំងពីរនាក់ជាអ្នកមានគុណខ្លួនទាំងពីរដូចគ្នា ព្រោះម៉ែ១ ឧបត្ថម្ភនេះ ម៉ែ១ ឧបត្ថម្ភនោះ ។ ម៉ែឈ្មោះ អស បានបែងចែកដីឱ្យប្អូនបង្កើតរបស់ឈ្មោះ ថសម ដែលមានទំហំ១៥មx១៩,៨០ម ដោយមានបញ្ជាក់ពីអាជ្ញាធរដឹងឮត្រឹមត្រូវ ។ ដំបូងនៅក្នុងសៀវភៅស្នាក់នៅមានសមាជិក១១នាក់ តែក្រោយមកគេក៏ចេញទៅរស់នៅអរិយក្សត្រ អស់ទៅ នៅតែ៤នាក់ទេ ដូចមានស្នាមឈូតឈ្មោះនោះ គឺជាឈ្មោះទេដែល

ត្រូវលុបចោល នៅក្នុងសៀវភៅឆ្នាំ៨១ ។ ក្នុងផ្ទះនេះ ក៏មានឈ្មោះ សសរ និងប្រពន្ធ បានមករស់នៅដោយអាផ្វាធរមូលដ្ឋាន បញ្ជាក់ដឹងឮ ក្រោយមកប្រពន្ធ សសរ បានស្លាប់ទៅ គាត់ក៏លក់ឱ្យ កផល បន្ត។ ខ្លួនដឹងត្រឹមថា មានអ្នក មកជួលផ្ទះ ក្រោយពេលម្តាយខ្លួនចេញទៅនៅវត្តកោះ ហើយ សច ក៏បានមកជួលនៅខាងលើ ខ្លួនពុំបានចាំពីឆ្នាំខែ ដែលគេមកជួលនោះទេ ។

បានស្តាប់ចម្លើយរបស់លោក សចជ បានឆ្លើយថា ផ្ទះនេះខ្លួននៅតាំងពីឆ្នាំ៨១មកម្ល៉េះ នៅ ពេលខ្លួនទៅរស់នៅនោះ ក៏មានឈ្មោះ អកស នៅពេលខ្លួនមករស់នៅនេះ គឺឪពុកឈ្មោះ សហ និងឈ្មោះ អស បានទៅយកខ្លួនមកនៅ ពេលនោះដែរខ្លួនមានអាយុជាង១០ឆ្នាំហើយ ។ក្រោយមកពួកគេផ្សេងទៀតបានចេញអស់ហើយ ខ្លួនពុំបានដឹងថា ពួកគេទៅរស់នៅកន្លែងណាទេ ប៉ុន្តែខ្លួនគ្រាន់តែដឹងថា នៅពេលម្តាយខ្លួនឈ្មោះ អស នេះស្លាប់ គឺគាត់ទៅស្លាប់នៅអឺរីយ៍ក្សត្រ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ...... ការពារឱ្យដើមចោទបញ្ជាក់ថា ទាក់ទងនឹងរឿងនេះ ខ្លួនសូមញែកចែកចេញជាពីរគឺ

- បញ្ហាសិទ្ធិកាន់កាប់គឺមានឈ្មោះ អស និងសមាជិករបស់គាត់មាន១១នាក់ ហើយក្នុង១១ នាក់នេះគឺគ្មានឈ្មោះ សចជ ទេ ពីឆ្នាំ៧៩មក ។

- បញ្ហាដែលទាក់ទងនឹងទ្រព្យមរតកគឺ នៅឆ្នាំ៨៤ ក្នុងបណ្ណគ្រួសារ ទើបឃើញមានឈ្មោះ សហ និង សចជ ។ ខ្លួនសូមបញ្ជាក់ផងដែរថា នៅក្នុងឆ្នាំ៨២ ឈ្មោះ សហ នៅមានប្រពន្ធដើមគាត់នៅឡើយទេ ហើយទំនាក់ទំនងរវាង សហ និង អស នេះមានលក្ខណៈជាប្តីប្រពន្ធលួចលាក់ទេ ហើយ សហ មករស់នៅក្រោយឈ្មោះ អស ទេដូចនេះផ្ទះនេះជាកម្មសិទ្ធិរបស់ អស ។ ផ្ទះនេះដំបូងឡើងគឺមាន៣គ្រួសារ មករស់នៅគឺអស, ថសម, សសរ ហើយ សសរ បានលក់បន្តឱ្យ កផល ដូចនេះ សហ គ្មានសិទ្ធិទាមទារផ្ទះនេះជាកម្មសិទ្ធិរបស់គាត់ទេ រីក៏គ្មានសិទ្ធិទាមទារជាទ្រព្យរួមដែរ។ទ្រព្យរបស់ អស គឺត្រូវធ្លាក់ទៅលើសាច់ញាតិគាត់សិន ទើបធ្លាក់ទៅលើទាយាទរបស់គាត់ ។ ឈ្មោះ អស បានស្លាប់នៅខែ៥-១៩៩៧ ហើយតាមលិខិតដែល អស បានចុះឈ្មោះ អកស ជាកូនចិញ្ចឹម ហើយតាមគោលការណ៍ច្បាប់ អកស ជាអ្នកទទួលមរតក ។ ឈ្មោះ ថសម មានសិទ្ធិលើដីទំហំ១៥ម គុណ
១៩,៨០ម និងឈ្មោះ កផល ដែលគេជាម្ចាស់កម្មសិទ្ធិត្រឹមត្រូវ ហើយសាលាឧទ្ធរណ៍បានសម្រេចពុំត្រឹមត្រូវទេ គឺវាប៉ះពាល់ដលផលប្រយោជន៍២នាក់ទៀត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក .......... ជាមេធាវីការពារឱ្យចុងចម្លើយបញ្ជាក់ ថាៈ ខ្លួនសូមបញ្ជាក់ថារឿងនេះ ខ្លួនបានដឹងច្បាស់លាស់ណាស់ គឺមាន៣តំណាក់កាលមកហើយដែលខ្លួនបានដឹងៈ

នៅឆ្នាំ៧៩ឈ្មោះ អស ជាអ្នកកាន់កាប់មែន ប៉ុន្តែពេលនោះ វាជាទ្រព្យរបស់រដ្ឋ មិនមែនជា របស់បុគ្គលណាទេ ។ ប្តីស្បិតតែគាត់ពុំទាន់ បានចងសម្ព័ន្ធជាប្តីប្រពន្ធនឹងគ្នា តែក្រោយមកគាត់ក៏បានចុះបញ្ជីជា

ប្តីប្រពន្ធ ដោយមានអាជ្ញាធរដឹងឮ ។ បើឈ្មោះ អកុស ជាកូនចិញ្ចឹម តើ អស ជាអ្នកបីបាច់ថែរក្សាឬទេ? ប៉ុន្តែគ្មានអាជ្ញាធរណាទទួលស្គាល់ថា អកល ជាកូនចិញ្ចឹមទេចំណែក ថសម នោះជាប្អូនថ្លៃទេ មិនមែនប្អូនបង្កើតទេ។ មានលិខិតដែលចុះឈ្មោះ អស ជាប្រពន្ធនិង សហ ជាប្តីផងដែរ ហើយ សចធ ជាកូនរបស់ សហ ហើយ អស ក៏ស្រលាញ់ សចធ ជាកូនដែរ។ហើយ សចធ បានដំដូងជាមួយឪពុកបាន១២ដើម ហើយក្រោយមកក៏បានដាំចេក ជុំវិញផ្ទះ ចាក់ដីបំពេញ ធ្វើបណ្តោញលូទឹក សព្វថ្ងៃនេះ ផ្ទះទំនាស់នេះទ្រុឌទ្រោមយ៉ាងខ្លាំង ។ ឈ្មោះ អស បានចែកដីឱ្យនោះ គួរតែប្រគល់ឱ្យ អកស ហេតុអ្វីក៏ប្រគល់ទៅឱ្យ ថសម និង យសវ ទៅវិញ ។ ការផ្ទេរសិទ្ធិប្រគល់ដីឱ្យយិននេះឈ្មោះ សហ ជាប្តីសុំបដិសេធទាំងស្រុងចោល នៅអាជ្ញាធរមូលដ្ឋានរួចហើយ ។ តាមលិខិតបំភ្លឺរបស់លោក សស ថាៈឈ្មោះ សសរ ស្នាក់នៅនោះបើម្ចាស់កម្មសិទ្ធិនោះទាមទារយកវិញ គាត់សន្យាថានឹងសងសវិញ ។ ខ្លួនសូមបង្ហាញសៀវភៅគ្រួសារដែលចុះហត្ថលេខា ឆ្នាំ២០០១ ។ ពេលលោក យសវ ស្លាប់ ទៅ លោក យកស ពុំទាន់ផ្លាស់ប្តូរត្រកូលទៅជា អកស នៅឡើយទេ ហើយក្រោយមក អ្នកស្រី ថសម ក៏បានទៅសុំលុបឈ្មោះប្តីឈ្មោះ យសវ នេះចោល ហើយក៏សុំប្តូរត្រកូលឱ្យកូនជាមួយប្តីដើមវិញ។ ចម្លើយសាក្សី រដ្ឋអំណាចមូលដ្ឋាន បានបញ្ជាក់ថា គាត់ទាំងពីនាក់នេះ ពិតជាប្តីប្រពន្ធនឹងគ្នា ដូចនេះ គាត់ក៏ត្រូវក្លាយទៅជាម្ចាស់កម្មសិទ្ធិរួចទៅហើយ ព្រោះវាជាទ្រព្យសម្បត្តិរួម ហើយពីឆ្នាំ៨៩ រហូតមកដល់ពេលស្លាប់នោះ គឺរយៈពេល១០ឆ្នាំ ហើយ ។ នៅឆ្នាំ៩២ មកគឺគ្មានឈ្មោះ អកស ចុះក្នុងសៀវភៅគ្រួសារទេ ។

សូមលោកចៅក្រម មេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ចសខ ជាមេធាវីការពារឱ្យដើមចោទបញ្ជាក់ បន្ថែមទៀតថា បើសិនជានៅឆ្នាំ៨១ មុនចេញអនុក្រិត្យនោះ គឺជាទ្រព្យរបស់រដ្ឋ ចុះហេតុអ្វីក៏មិនចុះឈ្មោះពី ពេលនោះមក ហើយប៉ាមកចុះនៅឆ្នាំ ៩៤ ទៅវិញ ។ បញ្ហាលោក អកស ជាកូនចិញ្ចឹមនោះ ក៏មានសាក្សី បំភ្លឺថា លោក អកល នៅជាមួយឈ្មោះ អស រហូតដល់ស្លាប់ហើយ អកស ត្រូវរស់នៅដោយ អស ជាអ្នកចិញ្ចឹម បីបាច់ថែរក្សា។ ឈ្មោះទេ ថសម ជាប្អូនបង្កើតរបស់ អស គឺគាត់ចែកឱ្យដាច់តែម្តងហើយ សសរ បានមកស្នាក់នៅពីឆ្នាំ៨០ មុនអនុក្រឹត្យចេញទៅទៀត ឯបញ្ហាបន្ទប់ជួលទាំងប៉ុន្មាននោះគឺបន្ទប់ ចាក់សោរចោល ពុំបានជួលឱ្យអ្នកណាទេ ហើយនៅឆ្នាំ៩៤ ឈ្មោះ អស ក៏បាននៅតែចុះឈ្មោះ អកស ជាកូនចិញ្ចឹមទៀត ។

ខ្ញុំសូមសំណូមពរ

១- ត្រូវរកឱ្យឃើញថា ទ្រព្យនោះជាទ្រព្យរបស់អ្នកណា

២- ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់

ខ្លួនសូមតម្កល់សារណារបស់ខ្លួននៅដដែល និងសូមបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក .......... ជាមេធាវីការពារឱ្យចុងចម្លើយបញ្ជាក់ បន្ថែមទៀតថា បើសិនជា អកល បានរស់នៅជាមួយ អស រហូតគាត់ស្លាប់ ហេតុអ្វីក៏លោក អកស ថាលោករស់នៅផ្ទះលេខ៥ . ទៅវិញ។ តាមពិត អស បានស្លាប់តែម្នាក់ឯងនៅអរីយ៍ក្សត្រទេគឺ អកស ពុំបានទាន់ដង្ហើម អស ស្លាប់ទេ ។

សូមលោកចៅក្រមមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣២៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៣ របស់មេធាវី .......... តំណាងឱ្យដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ឈ្មោះ អកស ក្នុងសារណា ចុះថ្ងៃទី០៩-០៣-០៤ ថាឈ្មោះ អស បានយកក្មួយបង្កើតគឺរូបខ្លួនមកធ្វើជាកូន ហើយបានចុះក្នុងប័ណ្ណគ្រួសារ មានអាជ្ញាធរដឹងឮ ហេតុនេះខ្លួនមានអានុភាពតាមផ្លូវច្បាប់ពេញលេញ ក្នុងការទទួលមរតកពីឈ្មោះ អស ជាម្តាយនោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា

- ប័ណ្ណគ្រួសារលេខ២១៧ សៀវភៅលេខ៣១/២៤-០១-៨១ ដែលមានឈ្មោះ អកស ជាកូននោះ ពុំមានលក្ខណៈគ្រប់គ្រាន់ អាចឱ្យតុលាការទទួលយកបានទេ ពីព្រោះនៅក្នុងប័ណ្ណ គ្រួសារនេះ មានឈ្មោះសមាជិកគ្រួសារចំនួន០៦ នាក់ ទៀតដែលដាក់ថា កូន ។
- ម៉្យាងទៀត ដើម្បីទទួលឋានៈជាកូនចិញ្ចឹម ទោះបីកាលៈទេសៈនោះ ពុំទាន់មានច្បាប់ក៏ដោយ ក៏យ៉ាងហោចណាស់ កូនចិញ្ចឹមនេះ ត្រូវមាននាមត្រកូលទៅតាមនាមត្រកូលរបស់ឪពុកឬម្តាយចិញ្ចឹម ហើយលោក អកស ក៏ពុំស្ថិតនៅក្រោមអំណាចមេបារបស់សពលោកយាយ អស ដែរ ។

-មានភស្តុតាំងបញ្ជាក់នៅឆ្នាំ១៩៨២ លោកយាយ អស បានទទួលយកឈ្មោះ សហ ជាប្តី ដូច្នេះ ផ្ទះ និងដី ពុំមែនជាកម្មសិទ្ធិរបស់ឈ្មោះ អស តែម្នាក់ទេ គឺជាសហកម្មសិទ្ធិរវាងឈ្មោះ អស និងឈ្មោះ សហ ។

- យល់ឃើញថា ផ្ទះទំនាស់នេះ ចុងចម្លើយបានកាន់កាប់ និងរស់នៅរួចហើយ ដូច្នេះពុំតម្រូវឲ្យដើមចោទ បង់ពន្ធសមាមាត្រទៀតទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៥៨ (ឈ) ចុះថ្ងៃទី ២២-១០-២០០៣ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

## ហេតុដូច្នេះ

## ទនិច្ឆ័យសេចក្ត ចំពោះមុខគូភ្ក

១- ទទួលបណ្តឹងសាទុក្ខលេខ៣២៦ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ របស់លោកមេធាវី ......... ទុកជាត្រឹមត្រូវទាំងទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ១៥៨(ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងពន្ធសមាមាត្រ ដែលត្រូវទុកជាមោឃៈ ដោយឥតបង្វិល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទ បានបង់រួចហើយនៅតុលាការកំពូលចំនួន១៩.០០០ រៀលគឺ:

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន១៥០០ រៀល សរុប១៩០០០ រៀល ។

៤- សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី០៩ខែកញ្ញា ឆ្នាំ២០០៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៤ ។